ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
ទេសរដ្ឋមន្ត្រី
លេខ ៣៣៦ កបទ.សអ/ច្បក២

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ជម្រាបមក

## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**កម្មវត្ថុ:** ករណីសុំកូនយកទៅចិញ្ចឹមរបស់ជនបរទេសតាមរយៈតុលាការ ។

ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមជ្រាបថា កន្លងមកមានការជួញដូរកុមារតាមរយៈការសុំកូន ។ ហេតុនេះហើយ ដើម្បីទប់ស្កាត់ការជួញដូរនេះ រាជរដ្ឋាភិបាលបានធ្វើអនុក្រឹត្យលេខ ២៩ អនក្រ-បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០១ ស្តីពីការសុំទារកកំព្រា ឬ កុមារកំព្រាយកទៅចិញ្ចឹមជាកូននៅឯបរទេស ។

ក៏ប៉ុន្តែបច្ចុប្បន្ននេះ ក្រសួងការបរទេសបានសង្កេតឃើញថា មានជនបរទេសជាច្រើនបានគេចវេស នីតិវិធីនៃការសុំកូនតាមអនុក្រឹត្យខាងលើនេះ ហើយទៅឃុបឃិតសុំកូន ឬទិញកុមារពីឪពុកម្តាយក្រៗ រួចទៅសុំតុលាការកាត់សេចក្តីសម្រេច ។ នេះជារូបភាពមួយនៃការជួញដូរកុមារកម្ពុជាយើង ដែលនឹងរួមគ្នាទប់ស្កាត់ ។ ចំពោះបញ្ហានេះក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារពុំមានមាត្រាណាដែលចែងថាឲ្យឪពុកម្តាយកាត់សេចក្តីព្រមប្រគល់កុមារកម្ពុជាឲ្យទៅជនបរទេសធ្វើជាកូនចិញ្ចឹមទេ ក៏ប៉ុន្តែដើម្បីការពារកុមារកម្ពុជាយើង តាមមាត្រា១១៣ នៃច្បាប់នេះចែងថា តុលាការអាចបដិសេធកិច្ចសន្យាសុំកូនតាមពាក្យបណ្តឹងរបស់កូនចិញ្ចឹមរបស់ជនទាំងឡាយ ឬអង្គការផ្សេងៗដែលធ្វើឡើងដើម្បីផលប្រយោជន៍របស់កូនចិញ្ចឹម ប៉ុណ្ណោះទេ ។

ក្រសួងការបរទេសយល់ឃើញថា ការសុំកូនតាមរយៈតុលាការរបៀបនេះម្យ៉ាងខុសនឹងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារផង ម្យ៉ាងទៀតខុសនឹងអនុក្រឹត្យខាងលើនោះផង ។

អាស្រ័យដូចបានជម្រាបខាងលើនេះ សូមឯកឧត្តមមេត្តាជ្រាប និងចាត់វិធានការទប់ស្កាត់តាមការគួរ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣

**ជ.រដ្ឋមន្ត្រី**

**អនុរដ្ឋលេខាធិការ**

**ឡុង វិសាលោ**

ចម្លងជូន
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនិតិសម្បទា
-តុលាការរាជធានីភ្នំពេញ